# ២៦- រឿង បុរសកំជិលមានប្រពន្ធគ្រប់លក្ខណ៍

មានរឿងព្រេងមួយដំណាលថា : មានបុរសកម្ជិលម្នាក់ មានប្រពន្ធគ្រប់លក្ខណ៍ មានកិរិយាមារយាទល្អ ចេះគោរពប្រណិប័តន៍ប្តី ។ តាំងពីបានគ្នាជាប្តីប្រពន្ធមក , បុរសកម្ជិលចេះតែពីដេក ដល់ឃ្លានបាយ ទើបក្រោកឡើងស៊ី ។ រួចដេកទៅវិញ សូម្បីថ្នាំជក់ ក៏ប្រពន្ធមូរឲ្យដែរ ។ ប្រពន្ធជាមនុស្សគោរពប្រណិប័តន៍ប្តី មិនមានពាក្យអាក្រក់ទៅលើប្តីសោះ លើកបាយទឹកនិងរបស់អ្វីឲ្យប្តី សុទ្ធតែសំពះ , ដល់ទៅយូរទៅ មានសេចក្តីក្រីក្រខ្លាំងណាស់ នាងនោះរកអ្វីចិញ្ចឹមពុំបានសោះឡើយ, ថ្ងៃមួយ នាងរៀបស្លា ៥ ម៉ាត់ បារី ៥ ចូលទៅក្រាបសំពះប្តី ហើយថា « ខ្ញុំសុំទោសអ្នកប្តីត្បិតយើងសព្វថ្ងៃក្រណាស់ យើងមិនបានរកស៊ី គ្មានទទួលទានទេ សុំឲ្យអ្នកទៅកាប់ឈើ ធ្វើនង្គ័ល រនាស់ធ្វើស្រែនឹងគេ ត្បិតដល់រដូវធ្វើស្រែហើយ » ។ ប្តីថាបើដូច្នោះ ឲ្យនាងដាំបាយ វេចជាសំណុំចុះ ប្តីនឹងទៅរកកាប់ឈើ ធ្វើនង្គ័ល រនាស់ ។ ប្រពន្ធក្រោកពីយប់ដាំបាយ វេចជាកញ្ចប់ មានទាំងដឹង ពូថៅទៅផង ។ បុរសកម្ជិលដេកទាល់តែថ្ងៃរះប្រពន្ធពុំហ៊ានដាស់ ចាំឲ្យក្រោកខ្លួនឯង, ដល់ក្រោកហើយ ប្រពន្ធដងទឹកទៅលប់មុខឲ្យរួចស្រេច នាងក៏ហុចស្លាបារីនឹងបាយកញ្ចប់ ព្រមទាំងគ្រឿងប្រដាប់ទៅឲ្យប្តី ។ បុរសនោះក៏ចុះពីលើផ្ទះទៅចូលក្នុងព្រៃរកឈើ, បានឃើញឈើមួយដើម មានមែកសាខាម្លប់ជាក់ ក៏ដាក់បាយសំណុំ ដឹង ពូថៅ ហើយដេកគងអន្ទាក់ខ្លា មើលទៅលើនិយាយតែម្នាក់ឯងថា «មែកឈើនេះ ត្រូវធ្វើជាផ្ទៀងនង្គ័ល, មែកនេះត្រូវធ្វើជាយាម , មែកនេះត្រូវធ្វើជាដង មែកនេះត្រូវជានឹមមែកនេះត្រូវធ្វើជារនាស់ ។ គ្រាន់តែដេកថាប៉ុណ្ណឹង ពេលឃ្លានបាយក្រោកឡើងស្រាយបាយសំណុំស៊ី ។រួច ដេកថាដូចមុនទៀត , ថ្ងៃរសៀលត្រឡប់មកផ្ទះវិញ» ។ ប្រពន្ធឃើញរត់ទទួលយកគ្រឿងប្រដាប់ នាំប្តីឡើងទៅលើផ្ទះ យកទឹកលាងជើងឲ្យប្តី ហើយសួរថា «អ្នកទៅបានការដូចម្តេចខ្លះ ? ប្តីថាមិនទាន់បានទេនាង ! ចាំស្អែកសឹមទៅទៀតដល់កន្លែងដើមឈើនោះហើយ, រុក្ខទេវតាដែលអាស្រ័យនៅទីនោះ ឮបុរសកម្ជិលថាដូច្នោះ ក៏ភ័យ ខ្លាចរកកន្លែងនៅគ្មាន ក៏គិតគ្នានឹងតាមទៅវាយសម្លាប់បុរសកម្ជិលនោះ ឲ្យស្លាប់នៅមាត់ជណ្តើរផ្ទះ កុំឲ្យវាមកកាប់ឈើនេះបាន ។ បុរសនោះក៏ត្រឡប់មកផ្ទះវិញ ។ រុក្ខទេវតា តាមមកដល់មាត់របង ឃើញប្រពន្ធរត់ទៅទទួលប្តីដល់មាត់ជណ្តើរ យកទឹកលាងជើងប្តី ។ ដោយសិរីសួស្តីប្រពន្ធនោះ ទេវតាចូលមិនចុះ មិនហ៊ានវាយ ។ បុរសនោះរួចពីអន្តរាយ ក៏ឡើងទៅលើផ្ទះ ប្រពន្ធសួរ និយាយដូចមុនទៀតថា « បានសព្វគ្រប់អស់ហើយ ព្រឹកនឹងទៅកាប់» ។ ទេវតាភ័យណាស់ថា « បុរសនោះ មុខជាកាប់ហើយព្រឹកនេះ » ក៏នាំគ្នាមកនិយាយអង្វរថា «សុំកុំកាប់ឈើនោះ»។ បុរសថា « អញមិនព្រមទេ ព្រឹកនេះអញទៅកាប់ហើយ» ។ ទេវតាភ័យណាស់ ក៏នាំគ្នានិយាយសូក ដោយប្រាប់ទីកន្លែងកំណប់មាសប្រាក់ឲ្យបុរស ។សួរថា « ឲ្យកំណប់ប៉ុន្មានកន្លែង ? » ។ ទេវតាថាពីរកន្លែង បុរសថា « មិនព្រមទេ, បើ ៤ កន្លែងទើបព្រមហើយឲ្យដាក់ឈើសម្គាល់ឲ្យផង » ។ ទេវតាក៏ព្រមធ្វើតាម កុំឲ្យតែកាប់ដើមឈើនោះ ។ បុរសថា « បើដូច្នោះ ខ្ញុំលែងកាប់ , តែថាព្រឹកនេះ ខ្ញុំទៅគាស់កំណប់នោះហើយ » ។ ទេវតាថា « ទៅចុះខ្ញុំដោតឈើសម្គាល់ទុកឲ្យ » ។ ព្រឹកឡើងប្តីប្រពន្ធ នាំគ្នាទៅគាស់កំណប់ដែលទេវតាឲ្យ, ក្នុងកំណប់មួយៗទាំងពីរនាក់ប្តីប្រពន្ធ ត្រូវជញ្ជូនបីថ្ងៃ បានសុទ្ធតែមាសនិងប្រាក់ចាក់គរពេញផ្ទះ ។ នាងនោះ ក៏រៀបចំដាក់ហិប ដាក់ឡាំង មិនឲ្យអ្នកណាឃើញ ហើយក៏ជួលជាងឲ្យធ្វើគ្រឿងប្រដាប់ លក់ជាជំនួញរឹតតែមានឡើងៗ បានជាសេដ្ឋី មានមនុស្សកុះករមូលមកនៅពឹងពាក់ជាច្រើន រាប់មិនអស់ ។